ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛

សុន្ទរកថាស្វាគមន៍

របស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់

អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

កិច្ចប្រជុំពិគ្រោះយោបល់កម្រិតនយោបាយលើកទី ១២

រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន

ស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុន

វិមានរដ្ឋាភិបាល ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤

- ឯកឧត្តម ***Yuji KUMAMARU*** *ឯកអគ្គរដ្ឋទូតជប៉ុន*

- ឯកឧត្តម ***Hiroshi IZAKI*** *ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំនៅកម្ពុជា និងសមាជិកគណៈប្រតិភូជប៉ុន*

- ឯកឧត្តម លោកជំទាវ សហសេវិកក្នុងរាជរដ្ឋាភិបាល

- លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

១- ខ្ញុំមានកិត្តិយស និងមានក្តីសោមនស្សរីករាយ សូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី ១២ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន នាពេលព្រឹកនេះ ។ កិច្ចស្វាគមន៍របស់ខ្ញុំក៏សូមផ្តល់ជូនចំពោះឯកឧត្តម *Yuji KUMAMARU* ឯកអគ្គរដ្ឋទូតជប៉ុន និងសមាជិកគណៈប្រតិភូជប៉ុន ពិសេស សមាជិកដែលបានអញ្ជើញមកពីទីស្នាក់ការកណ្តាល ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក តំណាងក្រសួង និងស្ថាប័ននៃរាជរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំនេះ ។

២- ដូចលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក បានជ្រាបហើយថា ជប៉ុនបានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងដំណើរការនៃការពង្រឹងសុខសន្តិភាព និងឯកភាពជាតិរបស់កម្ពុជា ហើយក៏ជាដៃគូដ៏សំខាន់ ដែលបានផ្តល់ហិរញ្ញប្បទានយ៉ាងច្រើន សម្រាប់ចូលរួមអភិវឌ្ឍសង្គម- សេដ្ឋកិច្ចកម្ពុជា ។ ការប្រារព្ធខួបអនុស្សាវរីយ៍លើក ទី៦០ នៃចំណងមិត្តភាពកម្ពុជា- ជប៉ុន នាខែ កុម្ភៈ ឆ្នាំ ២០១៣ កន្លងមក បានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងជាប្រវត្តិសាស្រ្ត ដែលត្រូវបានពង្រឹង និងពង្រីករវាងប្រទេស និងប្រជាជាតិទាំង ២ ។ ទន្ទឹមនឹងនេះ ក្នុងដំណើរទស្សនកិច្ចនៅទីក្រុងតូក្យូ កាលពីខែ ធ្នូ ឆ្នាំ ២០១៣ កន្លងមក **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងឯកឧត្តម **Shinjo ABE** នាយករដ្ឋមន្ត្រីជប៉ុន បានព្រមព្រៀងតម្លើងឋានៈនៃទំនាក់ទំនងរបស់ប្រទេសទាំង ២ ឱ្យដល់កម្រិត «**ដៃគូយុទ្ធសាស្រ្ត**» ដើម្បីបន្តពង្រឹង និងពង្រីកវិសាលភាពនៃកិច្ច

សហប្រតិបត្តិការ ឱ្យបានទូលំទូលាយបន្ថែម ក្នុងគោលដៅជំរុញកិច្ចអភិវឌ្ឍន៍កម្ពុជាឱ្យកាន់តែមានកម្រិតខ្ពស់ថែមទៀត និងប្រកបដោយចីរភាព តាមរយៈការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ និងការបង្កើនវិនិយោគជប៉ុននៅកម្ពុជា ។ លើសពីនេះ តាមសំណើរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ឯកឧត្តម **Shinjo ABE** នាយករដ្ឋមន្ត្រីជប៉ុន បានឯកភាពផ្តល់ការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា ក្នុងការធ្វើកំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា ហើយក្រុមអ្នកឯកទេសជប៉ុនបានចាប់ផ្តើមពិភាក្សាការងារ ជាមួយសមភាគីកម្ពុជា ចាប់ពីខែ ឧសភា កន្លងមក ។ លើសពីនេះ ជប៉ុនបានផ្តល់ជំនួយបន្ទាន់ ដល់រាជរដ្ឋាភិបាល សម្រាប់សង្គ្រោះប្រជាជនកម្ពុជារងគ្រោះដោយសារទឹកជំនន់ធ្ងន់ធ្ងរ នាឆ្នាំ ២០១១ និងឆ្នាំ ២០១៣ កន្លងមក ។ ក្នុងស្មារតីនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងអំណរគុណយ៉ាងជ្រាលជ្រៅ តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូត **Yuji KUMAMARU** ជូនចំពោះឯកឧត្តមនាយករដ្ឋមន្ត្រីជប៉ុន **Shinjo ABE** រដ្ឋាភិបាល និងប្រជាជនជប៉ុន ដែលបានផ្តល់ការគាំទ្រសម្រាប់អភិវឌ្ឍកម្ពុជា ទោះបីជប៉ុនកំពុងស្តារស្ថានភាពរងគ្រោះពីគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរបណ្តាលមកពីការរញ្ជួយដី និងរលកយក្ស Tsunami និងវិបត្តិរោងចក្រថាមពលនុយក្លេអ៊ែរ ក៏ដោយ ។

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក

៣- ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី ផ្អែកតាមប្រព័ន្ធទិន្នន័យរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ចាប់ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០១៣ ជប៉ុនបានផ្តល់ហិរញ្ញប្បទាន ចំនួនជាង ២.៤០០លានដុល្លា ស្មើនឹង ១៦% នៃហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ។ ក្នុងឆ្នាំ ២០១៣ ជប៉ុនបានផ្តល់ហិរញ្ញប្បទាន ចំនួន ១៥៦លានដុល្លា ក្នុងនោះ ហិរញ្ញប្បទានឥតសំណង ចំនួន ១១៣លានដុល្លា និងកម្ចីសម្បទាន ចំនួន ៤៣លានដុល្លា ហើយក្នុងឆ្នាំ ២០១៤ ទំហំហិរញ្ញប្បទានអាចមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ ២០១៣ ដែរ សម្រាប់គាំទ្រដល់វិស័យអាទិភាពជាច្រើនរបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ ការផ្តល់ហិរញ្ញប្បទានជប៉ុនបានជួយពន្លឿនការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ក៏ដូចជាជួយពន្លឿនការឈានឡើងរបស់កម្ពុជា ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ លើសពីនេះ ភាគីទាំង ២ បានចុះហត្ថលេខាលើលិខិតប្តូរសារ សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានឥតសំណងចំនួន ៤ និងបានត្រៀមចុះហត្ថលេខា នាពេលឆាប់ៗខាងមុខ នូវគម្រោងកម្ចីសម្បទានចំនួន ០៣ និងគម្រោងហិរញ្ញប្បទានឥតសំណង ចំនួន ១ គម្រោង ដែលមានតម្លៃសរុប ប្រមាណ ១៨១ លានដុល្លា ។ នេះបានបង្ហាញអំពីការប្តេជ្ញារបស់ភាគីទាំងសងខាង ក្នុងការពង្រឹង**ភាពជាដៃគូជាយុទ្ធសាស្ត្រ** ស្របតាមការសម្រេចរបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំង ២ ។

លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

៤- ក្នុងកិច្ចសហប្រតិបត្តិការតំបន់ ជប៉ុនបានដើរតួនាទីកាន់តែសំខាន់ឡើងៗ ក្នុងការជំរុញតំបន់មេគង្គឱ្យមានការអភិវឌ្ឍន៍ស្មើៗគ្នា និងមានលទ្ធភាពប្រកួតប្រជែង ។ គំនិតផ្តួចផ្តើមរបស់ជប៉ុនជាច្រើន ដូចជា **ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន-ជប៉ុន** (ASEAN-Japan Comprehensive Economic Partnership) **កិច្ចសហប្រតិបត្តិការមេគង្គ-ជប៉ុន** (Mekong-Japan Cooperation) **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ជប៉ុន** (The ASEAN-Japan Free Trade Agreement) **ផែនការសកម្មភាពទសវត្សនៃការអភិវឌ្ឍបៃតងនៅតំបន់មេគង្គ** (A Decade toward the Green Mekong Plan of Actions 2010-2020) ជាដើម ត្រូវបាន និងកំពុងអនុវត្ត ។

ទន្ទឹមនឹងនេះ ហេដ្ឋារចនាសម្ព័ន្ធក្រោមហិរញ្ញប្បទានរបស់ជប៉ុនដល់កម្ពុជា ពិសេស ស្ពានអ្នកលឿង ផ្លូវជាតិលេខ ១ និងផ្លូវជាតិលេខ ៥ បានជំរុញឱ្យមានការតភ្ជាប់ជារូបវ័ន្ត ក្នុងក្របខណ្ឌ**កម្មវិធីអនុតំបន់មេគង្គ** (Mekong Sub-region) ដែលជាផ្នែកមួយនៃការតភ្ជាប់អាស៊ាន (ASEAN Connectivity) និងបានផ្តល់ការគាំទ្រសម្រាប់អនុវត្តគម្រោងក្នុងក្របខណ្ឌ**កិច្ចអភិវឌ្ឍន៍ត្រីភាគី- កម្ពុជា ឡាវ និងវៀតណាម** (CLV Triangle Development) និង**កិច្ចសហប្រតិបត្តិការរវាងកម្ពុជា ឡាវ ភូមា និងវៀតណាម** (CLMV Cooperation) ។ ជាងនេះទៅទៀត ជប៉ុនបានផ្តល់ការគាំទ្រសម្រាប់អនុវត្ត**គំនិតផ្តួចផ្តើមនៃសមាហរណកម្មអាស៊ាន** (Initiative for ASEAN Integration-IAI) តាមរយៈការអនុវត្តផែនការសកម្មភាព- ដំណាក់កាលទី ២ (IAI Work Plan II) ដែលបាន ចាប់ផ្តើមអនុវត្តពីឆ្នាំ ២០០៩ រហូតដល់ឆ្នាំ ២០១៥ ដើម្បីឈានទៅសម្រេច**ទស្សនវិស័យអាស៊ាន ឆ្នាំ ២០២០** ។

៥- ក្នុងបរិបទបំរែបំរួលអាកាសធាតុ ជប៉ុនបានផ្តួចផ្តើមគំនិតបង្កើតកម្មវិធីជាច្រើន ដូចជា **កម្មវិធីបន្ថយកំដៅផែនដី** (Cool Earth Promotion Program) **ភាពជាដៃគូក្នុងការបន្ថយកំដៅផែនដី** ដោយសហការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (Cool Earth Partnership with Developing Countries) ។ សម្រាប់កម្ពុជា ជប៉ុនបានផ្តល់ឧបករណ៍ និងគ្រឿងចក្រដល់ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចូលរួមក្នុងកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗ ព្រមទាំងការងារអភិរក្សព្រៃឈើ ។

៦- សរុបមក ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការជប៉ុន ទាំងក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ទាំងក្នុងកិច្ចសហប្រតិបត្តិការក្នុងតំបន់ បានឆ្លើយតបនឹងតម្រូវការអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុង**យុទ្ធសាស្រ្តចតុកោណ** និង**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** ។ ក្នុងស្មារតីនេះ ភាពជាដៃគូរវាងប្រទេសទាំង ២ បានចាក់គ្រឹះយ៉ាងរឹងមាំ ហើយបានផ្តោតទៅលើលទ្ធផល ដោយផ្អែកលើ**គោលការណ៍ភាពជាម្ចាស់ ភាពជាដៃគូ** និង**ភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល** ។

លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក

៧- ចំពោះកិច្ចប្រជុំពិគ្រោះយោបល់លើកនេះ ដូចសព្វមួយដង គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) បានរៀបចំកិច្ចប្រជុំនេះ ដោយបានសហការយ៉ាងជិតស្និទ្ធ ជាមួយស្ថានទូតជប៉ុន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ។ កិច្ចប្រជុំលើកនេះមានគោលដៅសំខាន់ៗ ២ គឺ ÷

១- លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយ និងកម្មវិធីផ្តល់ហិរញ្ញប្បទានជប៉ុនដល់កម្ពុជា ដើម្បីធានាឱ្យមានសង្គតិភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការជប៉ុន ជាមួយនឹងអាទិភាពក្នុងការអភិវឌ្ឍកម្ពុជា ។

២- រួមគ្នាពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោង និងកម្មវិធីក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការជប៉ុន បន្ទាប់ពីកិច្ចពិគ្រោះយោបល់លើកទី ១១ នាខែ វិច្ឆិកា ឆ្នាំ ២០១១ កន្លងមក ។

ខ្ញុំសូមជម្រាបលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ជ្រាបថា កិច្ចពិគ្រោះយោបល់លើកនេះ ត្រូវបានដំណើរការ បន្ទាប់ពីរាជរដ្ឋាភិបាលបានអនុម័ត**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤-២០១៨** ដែល**ផែនការយុទ្ធសាស្រ្តនេះ** បានកំណត់គោលដៅ និងអាទិភាពសម្រាប់អភិវឌ្ឍប្រទេសជាតិ ។ នៅវេលារសៀលថ្ងៃនេះ នឹងមានសិក្ខាសាលាពន្យល់អំពីនីតិវិធីនៃការលើកគម្រោងស្នើហិរញ្ញប្បទានឥតសំណងសម្រាប់ឆ្នាំ២០១៥ ។ខ្ញុំសង្ឃឹមជឿជាក់ថា

ភាគីទាំងសងខាងនឹងសហការរៀបចំគម្រោង និងកម្មវិធីអាទិភាព ដើម្បីចូលរួមអនុវត្តឱ្យបានសម្រេច នូវបណ្តាគោលដៅនៃ**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** ។ ទន្ទឹមនឹងនេះដែរ កិច្ចពិគ្រោះយោបល់លើកនេះ មានលក្ខណៈទូលំទូលាយជាងលើកមុនៗ ព្រោះថា ការពិភាក្សានឹងផ្តោតលើគម្រោង និងកម្មវិធីទាំងអស់ក្នុងក្របខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការជប៉ុន រួមទាំងហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានជាកម្ចី ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

៨- រាជរដ្ឋាភិបាលបានចាត់ទុកកិច្ចពិគ្រោះយោបល់នេះ ជាកិច្ចដំណើរការដ៏សំខាន់ សម្រាប់បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងប្រទេសទាំងពីរ ហើយនេះក៏ជាកាលានុវត្តភាពដ៏ប្រពៃ សម្រាប់ពិភាក្សាអាទិភាព និងវិស័យ សម្រាប់ភាគីមិត្តធ្វើជាមូលដ្ឋានក្នុងការផ្តល់ហិរញ្ញប្បទាន សម្រាប់រយៈពេលខាងមុខ និងផ្តល់កាលានុវត្តភាពពិភាក្សាបញ្ហាប្រឈមទាំងឡាយ ដែលបានជួបប្រទះក្នុងពេលអនុវត្តគម្រោង និងកម្មវិធី ។

៩- ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ជូនរដ្ឋាភិបាល និងប្រជាជនជប៉ុនដែលជាអ្នកបង់ពន្ធទាំងអស់ថា ហិរញ្ញប្បទានដែលបានផ្តល់កន្លងមក ត្រូវបានប្រើប្រាស់ប្រកបដោយតម្លាភាព និងគណនេយ្យភាព ក្នុងបុព្វហេតុអភិវឌ្ឍន៍កម្ពុជា ។ មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ដែលបានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ នាពេលនេះ ។ ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំជាផ្លូវការ ចាប់ពីពេលនេះ ហើយខ្ញុំសូមជូនពរឱ្យកិច្ចពិភាក្សាទទួលលទ្ធផលប្រកបដោយផ្លែផ្កា ។

សូមអរគុណ